ព័ត៌មានទាក់ទងរបស់
កិច្ចបំរើសុខភាពកុមារ និងគ្រួសារ

StEPs
Statewide Eyesight
Preschooler Screening

SHPN (NKF) 130149 - Khmer

# StEPs

# ការពិនិត្យមើលចក្ខុវិញ្ញាណ (ការមើលឃើញ) សម្រាប់ក្មេងរៀន នៅសាលាត្រៀមពេញទូទាំងរដ្ឋ

Statewide Eyesight Preschooler Screening



## អ្វីដែលលោកអ្នកត្រូវការដឹងអំពីកម្មវិធី StEPS

NSW GOVERNMENT | Health

## តើ StEPS ជាអ្វី?

កម្មវិធី StEPS គឺជាគម្រោងការផ្តួចផ្តើមរបស់ក្រសួងសុខាភិបាលរដ្ឋញូវសៅវែល ហើយផ្តល់ជូនការពិនិត្យមើលចក្ខុវិញ្ញាណដោយឥតគិតថ្លៃសម្រាប់ក្មេងអាយុ៤ឆ្នាំទាំងអស់។

## ហេតុអ្វីបានជាកូនរបស់ខ្ញុំត្រូវការពិនិត្យមើលចក្ខុវិញ្ញាណរបស់គេ?

- ក្មេងកម្រត្អូញត្អែរអំពីបញ្ហាភ្នែករបស់គេណាស់
- ក្មេងប្រហែលជាពុំដឹងថាគេមិនអាចមើលឃើញច្បាស់ឡើយ
- ក្មេងខ្លះអាចមើលឃើញច្បាស់ដោយភ្នែកម្ខាង ក៏ប៉ុន្តែមានចក្ខុវិញ្ញាណអន់ថយក្នុងភ្នែកម្ខាងទៀត
- ភ្នែករបស់ក្មេងអាចឃើញដូចជាពុំមានបញ្ហាអ្វីឡើយ ហើយឪពុកម្តាយ /អ្នកមើលថែអាចគិតថាកូនរបស់គេអាចមើលឃើញច្បាស់ ក៏ប៉ុន្តែក្មេងខ្លះនៅតែអាចមានបញ្ហាចក្ខុវិញ្ញាណដដែល
- របៀបតែមួយគត់ដើម្បីឲ្យបានដឹងថាតើក្មេងណាម្នាក់មានបញ្ហាភ្នែកឬអត់ គឺត្រូវធ្វើតេស្តភ្នែករបស់ក្មេងម្តងមួយៗ។



## តើលោកអ្នកដឹងឬទេថា?

- ប្រសិនបើក្មេងមាន 'រោគមើលពុំឃើញភ្នែកម្ខាង' វាអាចនាំឲ្យបាត់បង់ចក្ខុវិញ្ញាណយ៉ាងធ្ងន់ធ្ងរ ឬការខ្វាក់ក្នុងភ្នែកមួយនោះ ប្រសិនបើពុំបានព្យាបាល
- ប្រសិនបើក្មេងមានបញ្ហាចក្ខុវិញ្ញាណ ការរកឃើញបញ្ហាបានទាន់ពេល ហើយព្យាបាលបានកាន់តែឆាប់ នោះលទ្ធផលនៃចក្ខុវិញ្ញាណរឹតតែប្រសើរឡើង
- ប្រសិនបើឪពុកម្តាយពាក់វ៉ែនតា ឬមានបញ្ហាចក្ខុវិញ្ញាណកាលពីនៅវ័យក្មេង នោះកូនរបស់គេក៏ទំនងជាមានបញ្ហាចក្ខុវិញ្ញាណដែរ
- ក្រោយពេលអាយុប្រាំបីឆ្នាំ បញ្ហាចក្ខុវិញ្ញាណរបស់ក្មេងមួយចំនួនពុំអាចព្យាបាលបានឡើយ ហើយក្មេងទាំងនោះនឹងមានចក្ខុវិញ្ញាណអន់ថយក្នុងមួយជីវិតរបស់គេ – វ៉ែនតានឹងពុំអាចជួយបានឡើយ
- ទារកដែលមានទម្ងន់ស្រាលនៅពេលកើតមក និងក្មេងដែលមានបញ្ហាសរសៃប្រសាទ ប្រឈមមុខនឹងគ្រោះថ្នាក់ដ៏សម្បើមនៃការកើតមានបញ្ហាភ្នែក

## តើកូនរបស់ខ្ញុំត្រូវការពិនិត្យមើលចក្ខុវិញ្ញាណរបស់គេឬទេ?

ក្រសួងសុខាភិបាលរដ្ឋញូវសៅវែល ដាស់តឿនក្មេងទាំងអស់ឲ្យពិនិត្យមើលចក្ខុវិញ្ញាណរបស់គេ មុនពេលគេចាប់ផ្តើមចូលសាលារៀន ហើយបានណែនាំយ៉ាងខ្លាំងឲ្យក្មេងអាយុ៤ឆ្នាំទាំងអស់ចូលរួមក្នុងកម្មវិធីពិនិត្យមើលចក្ខុវិញ្ញាណ។

## តើកូនរបស់ខ្ញុំអាចមានលទ្ធភាពទទួលកម្មវិធី StEPS ដោយបែបណា?

មន្ទីរសុខភាពនៅតំបន់លោកអ្នក នឹងតម្រង់គោលដៅចំពោះសាលាត្រៀម និងមជ្ឈមណ្ឌលថែទាំក្មេង ដើម្បីផ្តល់ជូនការពិនិត្យមើលចក្ខុវិញ្ញាណ**ដោយឥតគិតថ្លៃ**សម្រាប់ក្មេងអាយុបួនឆ្នាំទាំងអស់។ ដើម្បីឲ្យគេពិនិត្យមើលចក្ខុវិញ្ញាណរបស់កូនលោកអ្នក លោកអ្នកនឹងត្រូវបំពេញហ្វ៊មយល់ព្រមមួយ រួចបញ្ជូនវាទៅសាលាត្រៀម /មជ្ឈមណ្ឌលថែទាំកូនរបស់លោកអ្នកវិញ។

លោកអ្នកក៏អាចឲ្យគេពិនិត្យមើលចក្ខុវិញ្ញាណ**ដោយឥតគិតថ្លៃ** សម្រាប់កូនអាយុបួនឆ្នាំរបស់លោកអ្នកបានដែរ តាមរយៈកិច្ចបំរើសុខភាពកុមារ និងគ្រួសារក្នុងតំបន់របស់លោកអ្នក។ ព័ត៌មានទាក់ទងរបស់កិច្ចបំរើសុខភាពកុមារ និងគ្រួសារក្នុងតំបន់របស់លោកអ្នក មានចុះនៅផ្នែកខាងក្រោយនៃសន្លឹកព័ត៌មាននេះ។



## តើខ្ញុំនឹងដឹងថាកូនរបស់ខ្ញុំមានបញ្ហាចក្ខុវិញ្ញាណដោយបែបណា?

ឪពុកម្តាយ /អ្នកមើលថែគ្រប់រូបនៃក្មេងដែលបានទទួលការពិនិត្យមើលចក្ខុវិញ្ញាណ នឹងបានទទួលដំណឹងអំពីលទ្ធផលនៃការវាយតម្លៃលើការពិនិត្យមើលចក្ខុវិញ្ញាណរបស់កូនគេ។ ប្រសិនបើបញ្ហាចក្ខុវិញ្ញាណត្រូវបានរកឃើញ មន្ទីរសុខភាពនៅតំបន់របស់លោកអ្នកនឹងទាក់ទងមកលោកអ្នក ហើយស្នើសុំធ្វើតេស្តភ្នែកកូនរបស់លោកអ្នក ឲ្យបានពេញលេញដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាពភ្នែក។

ដោយព្រោះថាភ្នែករបស់ក្មេងបន្តលូតលាស់ រហូតដល់អាយុប្រមាណ៨ឆ្នាំ នេះគឺជាការសំខាន់ដែលត្រូវធ្វើឲ្យប្រាកដថា ចក្ខុវិញ្ញាណរបស់ក្មេងគ្រប់រូបលូតលាស់តាមធម្មតាគ្រប់ពេលក្នុងឆ្នាំលូតលាស់ទាំងនេះ។

កម្មវិធី StEPS គឺជាកម្មវិធីពិនិត្យមើលចក្ខុវិញ្ញាណ ហើយពុំផ្តល់ជូនការវាយតម្លៃផ្នែករោគវិនិច្ឆ័យពេញលេញឡើយ។ ប្រសិនបើលោកអ្នកមានក្តីកង្វល់ណាមួយអំពីចក្ខុវិញ្ញាណរបស់កូនលោកអ្នក លោកអ្នកត្រូវបានណែនាំឲ្យធ្វើតេស្តចក្ខុវិញ្ញាណរបស់កូនលោកឲ្យបានពេញលេញ ដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាពភ្នែក។